76
14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ១៨២៦
ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៥
សំណុំរឿងជំនុំជម្រះលេខ ២៧៨៣
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥
សាលក្រមលេខ ២១៣-ច-ក្រ៣
ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ វេលាម៉ោង ៨ និង ០០ នាទី ព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោកជំទាវ [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៨២៦ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ដែលមានជនជាប់ចោទឈ្មោះ [redacted] NASWALL (ប្រាយអិន ដាវីដ ណាស្វែល) ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក មុខរបរ ម្ចាស់ភាគហ៊ុនអាកាសចរ AERO CAMBODIA AIRLING ទីកន្លែងកំណើតនៅទីក្រុង Winnipig ខេត្ត Manatoba ប្រទេសកាណាដា មានទីលំនៅស្នាក់នៅផ្ទះ [redacted] អាគារB ផ្លូវលេខ ២១១ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន ០១ នាក់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៥ ,ឃុំខ្លួនថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥

ពីបទការទិញពេស្យាចារកុមា ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ ២០១៥ និងជាក់ស្តែងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

លោកស្រី [redacted] ចំប៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

✓ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៧ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិសំរោង ឃុំខ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។

✓ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ២០១ ផ្លូវលេខ២១១ ភូមិ១២ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

✓ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិ១២(បុរីកីឡា) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅស្នាក់នៅផ្ទះជួល ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅភូមិសារាយ ឃុំបុស្សខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ ១៥ ឆ្នាំ កើតថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០០០ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] (ម.ក.ក.ស.ក) [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ៥ ឆ្នាំ កើតថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១០ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីឃីម ភេទស្រី អាយុ ៧ ឆ្នាំ កើតថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០០៨ សញ្ជាតិខ្មែរ [redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] សុភីនីដុតិមុន្នី ភេទស្រី អាយុ ៦ ឆ្នាំ កើតថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៩ សញ្ជាតិខ្មែរ មានទីលំនៅ [redacted] រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ១៣ ឆ្នាំ កើតឆ្នាំ ២០០២ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះ [redacted] រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] សុភ័ក្ត្រ ភេទស្រី អាយុ ១៦ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ ១៥ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] ង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ ១៣ ឆ្នាំ សញ្ជាតិខ្មែរ (ស្នាក់នៅសហគមន៍ទឹកដីសន្យា) [redacted] សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ១៣ ឆ្នាំ កើតថ្ងៃទី ០៥ ខែកក្កដាឆ្នាំ ២០០២ សញ្ជាតិខ្មែរ ( [redacted] ជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

លោកស្រី [redacted] សុនី និងលោក [redacted] ថុល ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៣៥៩ អយប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៦២២ ដ.ជ.រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

<u>**អង្គហេតុនៃរឿងមានដូចតទៅ៖**</u>



Scanned with CamScanner

កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ វេលាប្រហែល ១៩ និង ០០ នាទី នៅចំណុចកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] NASWALL ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក បានជិះម៉ូតូធំឌុបកុមាររងគ្រោះចំនួន បីនាក់ មានឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ ១៣ ឆ្នាំ ,ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ ១៦ ឆ្នាំ និងឈ្មោះ [redacted] ស្រីរ័ត្ន ភេទស្រី អាយុ ១៥ ឆ្នាំ ដើរលេង ហូបនំចំណី និងទិញសំភារៈផ្សេងៗឲ្យទៅជនរងគ្រោះ ។ ពេលមកដល់កោះពេជ្រកន្លែងស្ងាត់ ខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ ជនសង្ស័យឈ្មោះ [redacted] Naswall ក៏បានឈប់ម៉ូតូរួចក៏ស្រាតខោរបស់គេចេញ ក៏ឲ្យកុមាររងគ្រោះយកដៃ [redacted] របស់គេ រួចគេក៏យកដៃស្ទាប [redacted] របស់កុមាររងគ្រោះវិញ ដោយកុមាររងគ្រោះ ឈ្មោះ [redacted] ស្រីល័ក្ខ ដាក់អង្គុយលើម៉ូតូ រួចជនជាប់ចោទបានយកអ[redacted] របស់កុមាររងគ្រោះវិញ ។ ជនជាប់ជាប់ចោទបានសន្យាឲ្យប្រាក់ទៅកុមារនារីរងគ្រោះទាំងអស់នោះក្នុងមួយនាក់ៗ ចំនួនពី ១៥ ដុល្លារអាមេរិក ទៅ ២០ ដុល្លារអាមេរិក ក្រោយពីជនសង្ស័យឈ្មោះ [redacted] Naswall បានធ្វើសកម្មភាពបាន ប្រហែល ០៧ នាទី ក៏ត្រូវសមត្ថកិច្ច ចូលទៅធ្វើការខាត់ខ្លួន ជាក់ស្តែងតែម្តង ។ កន្លងមកនៅក្នុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ២០១៥ ជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នា ជនជាត់អាមេរិក ក៏បានសកម្មភាព ដូនេះទៅលើកុមាររងគ្រោះ ជាច្រើននាក់ ផ្សេងទៀតមកហើយ ។

## នាពេលសួរនាការ

ជនជាប់ចោទឈ្មោះ [redacted] Naswall បានឆ្លើយថា កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ វេលាម៉ោងប្រហែល ១៩ និង ០០ នាទី ទៅម៉ោង ២០ និង ០០ នាទី មានក្មេងស្រីម្នាក់ ដែលខ្លួនធ្លាប់ស្គាល់នៅមាត់ទន្លេ តែមិនស្គាល់ឈ្មោះបានទូរស័ព្ទមកខ្លួនសុំឲ្យខ្លួនជូននាងទៅលេងទ្រីមលេន ប៉ុន្តែពេលនោះ ខ្លួនបានប្រាប់នាងថាជាប់រវល់ ។ បន្ទាប់ពីនិយាយទូរស័ព្ទចប់ ខ្លួនបានជិះម៉ូតូធំចេញពីផ្ទះទៅរកហូបអី ពេលជិះម៉ូតូមកដល់ម្តុំមាត់ទន្លេ ស្រាប់តែក្មេងស្រី ដែលបានទូរស័ព្ទមកខ្លួនបានឃើញខ្លួន ហើយក៏ស្រែកហៅឲ្យឈប់ ។ ពេលនោះខ្លួនឃើញមានគ្នាចំនួន ០៣ នាក់ រួចក៏ឲ្យខ្លួនជូនទៅលេងឌ្រីមលេនទាំងបីនាក់ ដោយជិះម៉ូតូជាមួយគ្នាទាំងអស់ ។ បន្ទាប់ពីដើរលេងឌ្រីមលេន ដោយជិះកន្ត្រកវិល និងបានញ៉ាំអីរួចមក ពួកនាងក៏បានឲ្យខ្លួនជូនទៅគប់ប៉េងប៉ោងនៅកោះពេជ្រ ក្រោយពីគប់ប៉េងប៉ោងនៅកោះពេជ្រចប់ រួចខ្លួនក៏បានឌុបពួកនាងទៅកន្លែងមួយ ដែលមិនសូវមានមនុស្ស ប៉ុន្តែមិនស្ងាត់ពេកទេ ក្នុងបំណងទៅបត់ជើងតូច ។ ពេលខ្លួនឈប់ម៉ូតូក្មេងស្រី ដែលជិះទៅជាមួយ គឺបានដើរចេញពីខ្លួន ប៉ុន្តែមិនឆ្ងាយទេ រួចក៏ដើរទៅបត់ជើង ក្រោយពីបត់ជើងរួច ខ្លួនក៏មកកន្លែងម៉ូតូវិញ ស្រាប់តែមានមនុស្សប្រហែល ៥ ទៅ ០៦ នាក់ បានឈ្លូលពិលមករកខ្លួន ហើយស្រែកថា ប៉ូលីសៗ ហើយប្រាប់មកខ្លួនថា និងនាំខ្លួនទៅកន្លែងប៉ូលីស ដោយសារខ្លួនបានរួមភេទជាមួយអនីតិជន ហើយខ្លួនក៏យល់ព្រមទៅជាមួយប៉ូលីស ។ ពេលខ្លួនឈប់ម៉ូតូនៅកន្លែងស្ងាត់ គឺមិនបានឲ្យក្មេងៗទាំងនោះ [redacted] របស់ខ្លួននោះទេ ហើយខ្លួនក៏ [redacted] ភេទ ក្មេងស្រីៗទាំងនោះដែរ ហើយក៏មិនបានសន្យាទិញសំភារៈ និងលុយកាក់ដល់ក្មេងៗទេ ហើយកន្លងមក ក៏មិនដែលបានធ្វើអំពើដូចការចោទប្រកាន់ដែរ ។ ក្មេងស្រីៗទាំងបីនាក់ដែលខ្លួនជូនដើរលេងនៅយប់កើតហេតុ គឺខ្លួនធ្លាប់ស្គាល់ពួកនាង ដោយសារធ្លាប់ឃើញពួកនាងដើរលេងនៅម្តុំមាត់ទន្លេ ជាច្រើនលើកច្រើនសារ គឺមិនស្គាល់ឈ្មោះទេស្គាល់តែមុខ ហើយក៏មិនដែលមានទំនាក់ទំនងផ្លូវភេទជាមួយពួកនាងទេ ។ ខ្លួនធ្លាប់ស្គាល់ក្មេងបានប្រហែលមួយឆ្នាំទៅពីរឆ្នាំ និងធ្លាប់ដើរ



Scanned with CamScanner

លេងបានប្រហែល ៣ ដង និងធ្លាប់ឲ្យលុយ នាងផងដែរ ប៉ុន្តែមិនដែលបានឲ្យលើសពី ១ដុល្លារនោះទេ ហើយក៏មិនដែលសន្យាឲ្យប្រាក់នាង ពី២០ ដុល្លារ ទៅ ៣០ដុល្លារ នោះទេ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីណែត បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted] Naswall តាំងពីឆ្នាំ ២០១៣ ហើយបានដើរលេងជាមួយគាត់បានចំនួន ២ដង ។ លើកទី១ នៅក្នុងខែកក្កដា ឆ្នាំ ២០១៣ វេលាម៉ោង ១៩ និង ០០ នាទី ខ្លួនបានដើរលេងជាមួយឈ្មោះ ស្រីនាង បានជិះម៉ូតូធំ ជាមួយឈ្មោះ [redacted] Naswall នៅសួនច្បារកោះពេជ្រ ទៅដល់កន្លែងស្ងាត់ គាត់បានឲ្យរូបខ្លួន និងស្រីនាង [redacted] ភេទរបស់គាត់ ដោយគាត់បាន [redacted] របស់គាត់ រួចគាត់បានឲ្យប្រាក់ចំនួន ៥ ដុល្លារអាមេរិក ចែកគ្នា ។ លើកទី២ បន្ទាប់ពីលើកទី១ ប្រហែល ៥ ថ្ងៃ ពេលនោះខ្លួនទៅជាមួយឈ្មោះ ស្រី៧ នៅពេលយប់ឈ្មោះ Brian Davit Naswall បានឌុបពួកខ្លួនទាំងពីរនាក់ ដើរលេងសួនច្បារសម្ដេចហ៊ុន សែន ពេលដល់កន្លែងស្ងាត់ គាត់បានឲ្យរូបខ្លួន និងស្រីម៉ៅ [redacted] ភេទរបស់គាត់រួចខ្លួន និងឈ្មោះ ស្រីម៉ៅ លេងប្រដាប់ភេទរបស់គាត់ រួចខ្លួននិងឈ្មោះ ស្រីម៉ៅ យក [redacted] របស់គាត់ រហូតដល់ [redacted] រួចគាត់បានឲ្យប្រាក់ ៥ដុល្លារចែកគ្នា ។ ក្រោយមកទៀតក្នុងឆ្នាំ ២០១៤ និងឆ្នាំ ២០១៥ រូបខ្លួនមិនដែលជួបឈ្មោះ [redacted] Naswall ទៀតទេ ។

ជនរងគ្រោះឈ្មោះ [redacted] ស្រីរ័ត្ន បានឆ្លើយថា ខ្លួនបានដើរលេងជាមួយឈ្មោះ [redacted] Naswall បានចំនួន ២ដង ។ នៅថ្ងៃមិនចាំ ឆ្នាំ ២០១៣ វេលាម៉ោង ២៣ និង ០០ នាទី ខ្លួនបានជួបជនបរទេសម្នាក់ឈ្មោះ [redacted] Naswall នៅមាត់ទន្លេ ជាមួយមិត្តភ័ក្រ្តឈ្មោះ ស្រីម៉ៅ និងស្រីនាង បានជូនពួកខ្លួនជិះម៉ូតូធំដើរលេង ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២០ និង ៣០ នាទី រូបខ្លួន និងបងស្រីឈ្មោះ ស្រី៧ បានអង្គុយលេងនៅមាត់ទន្លេ ហើយបានជួបឈ្មោះ ភ័ក្រ ហៅ អូន និងឈ្មោះ ស្រីល័ក្ខ ហៅ ពេជ្រ ក៏បាននាំខ្លួនទៅដើរលេងជាមួយឈ្មោះ [redacted] Naswall ចំណែកប្អូនរបស់ខ្លួនឈ្មោះ ស្រីពេជ្រ មិនបានទៅទេ ។ ឈ្មោះ [redacted] Naswall បានឌុបពួកនាងទៅលេងកោះពេជ្រ កន្លែងការដ្ឋានសាងសង់ស្ងាត់មួយ គាត់បាន [redacted] របស់គាត់ ដោយគាត់បានសន្យាឲ្យប្រាក់មកខ្លួន និងឈ្មោះ ស្រីអូន ម្នាក់ចំនួន ១៥ ដុល្លារ ឯឈ្មោះ ស្រីពេជ្រ ចំនួន ២០ ដុល្លារ តែខ្លួន និងឈ្មោះ ស្រីអូន មិនព្រមយក រួចគាត់ឲ្យឈ្មោះ ស្រីពេជ្រ ឡើងអង្គុយលើកែបម៉ូតូ [redacted] គាត់ ហើយគាត់ [redacted] ស្រីពេជ្រ វិញ ប៉ុន្តែលេងមិនទាន់ចប់ផង ស្រាប់តែសមត្ថកិច្ចមកដល់ ។

ជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted] Naswall តាំងពីឆ្នាំ ២០១៤ នៅពេលដែលខ្លួនបានដើររើសអេតចាយនៅមាត់ទន្លេ និងគាត់ធ្លាប់ឲ្យប្រាក់មកខ្លួនចំនួន ៣ដង ពី ១ដុល្លារ ទៅ ៥០០០ រៀល និងធ្លាប់ដើរលេងជាមួយគាត់បានចំនួន ៣ដងដែរ និងលេងប្រដាប់ភេទគាត់ម្ដង គាត់បានឲ្យប្រាក់ ១០ដុល្លារ ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២០ និង ០០ នាទី ខ្លួនបានជួបឈ្មោះ [redacted] Naswall រួចក៏បបួលពួកខ្លួន ជិះម៉ូតូដើរលេង មានរូបខ្លួន ,ឈ្មោះ សុភ័ក្រ និងឈ្មោះ ស្រីរ័ត្ន ចំណែកឈ្មោះ ស្រី៧ មិនបានទៅទេ ។ ក្នុងពេលពួកខ្លួនជិះកន្ត្រកវិល ជាមួយឈ្មោះ [redacted] Naswall គឺគាត់ឲ្យពួកខ្លួនទាំងបី លេងប្រដាប់ភេទរបស់គាត់ គាត់បានរ៉ូតខោ [redacted] មកក្រៅ ឲ្យពួកខ្លួនលេង ហើយឈ្មោះ [redacted] Naswall ក៏បាន [redacted] ខ្លួនទាំងបីនាក់វិញផងដែរ រហូតដល់កន្ត្រកលែងវិល ទើបឈប់លេង ។ ឈ្មោះ [redacted] Naswall បានសន្យាឲ្យប្រាក់



Scanned with CamScanner

ក្នុងម្នាក់ៗ ១០ដុល្លារ ។ បន្ទាប់មកក៏បានឧបពួកខ្លួនទៅកោះពេជ្រ ពេលទៅដល់កន្លែងមួយ ដែលគេព័ទ្ធសង្កសីជិតសន្តិសុខយាម យប់ស្ងាត់ ឈ្មោះ [redacted] Naswall ក៏បានឲ្យពួកខ្លួនទាំងបីនាក់ [redacted]ទៀត ដោយបានសន្យាឲ្យប្រាក់មកខ្លួន និងឈ្មោះ ស្រីរ័ត្ន ក្នុងម្នាក់ ៥ដុល្លារ ថែមទៀត ចំណែកឈ្មោះ ស្រីល័ក្ខ គឺគាត់ថែមឲ្យ ១០ដុល្លារ ។ ពេលនោះខ្លួន និងឈ្មោះ ស្រីល័ក្ខ មិនបានលេងទេ ហើយឈ្មោះ [redacted] Naswall ក៏ឲ្យពួកខ្លួនទាំងពីរឈរឆ្ងាយ ដើម្បីចាំមើលផ្លូវឲ្យគាត់។ ពេលនោះខ្លួនឃើញឈ្មោះ [redacted] Naswall [redacted]ដាក់នាងឲ្យអង្គុយលើម៉ូតូ ហើយឈ្មោះ [redacted] Naswall ក៏បាន[redacted] មុខចេញ ស្រាប់តែមានសមត្ថកិច្ចមកចុះចាប់ខ្លួនតែម្តង ។ កន្លងមកពេលដែលរូបខ្លួនដើរលេងជាមួយឈ្មោះ ស្រីណែត និងឈ្មោះ ស្រីម៉ៅ គឺធ្លាប់បានឃើញឈ្មោះ [redacted] Naswall ឲ្យឈ្មោះ ស្រីម៉ៅ និងស្រីណែត [redacted]ទៅកោះពេជ្រផងដែរ ។ ប៉ុន្តែមិនបានដឹងថាឈ្មោះ [redacted] Naswall ឲ្យលុយទៅឈ្មោះ ស្រីម៉ៅ និងស្រីណែត ប៉ុន្មានទេ ។

ជនរងគ្រោះឈ្មោះ [redacted]ស្រីល័ក្ខ បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted]Naswall នៅមាត់ទន្លេតាមរយៈឈ្មោះ ភ័ក្រ ភេទស្រី ក្នុងឆ្នាំ ២០១៥ ។ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ១៩ និង ០០ នាទី ខ្លួនដើរលេងនៅមាត់ទន្លេជិតផ្សារកណ្តាល មានគ្នា ៤ នាក់ មានឈ្មោះ ភ័ក្រ ភេទស្រី អាយុ ១៦ ឆ្នាំ ,ឈ្មោះ ស្រីរ័ត្ន អាយុ ១៥ ឆ្នាំ ,ឈ្មោះ ស្រីពៅ អាយុ ១៤ ឆ្នាំ និងរូបខ្លួន ស្រាប់តែឈ្មោះ [redacted] Naswall បានជិះម៉ូតូមកឈប់ក្បែរពួកខ្លួន រួចបបួលពួកខ្លួនទៅដើរលេងនៅគ្រឹមលេន រួចពួកខ្លួនបីនាក់ក៏ព្រមទៅ ដោយឡែកឈ្មោះ ស្រីពៅ មិនបានទៅជាមួយទេ ។ ទៅដល់គ្រឹមលេន ឈ្មោះ [redacted] Naswall បានទិញការ៉េមឲ្យពួកខ្លួន គប់ប៉េងប៉ោង និងជិះកន្ត្រកវិល ។ ក្រោយពីលេងនៅគ្រឹមលេនរួច ឈ្មោះ [redacted] Naswall បានឧបពួកខ្លួនទៅកោះពេជ្រ ។ ដល់កន្លែងស្ងាត់ក្រោយឃ្លាំងធំមួយ គាត់បានឲ្យខ្លួ[redacted]គាត់ ហើយគាត់សន្យាឲ្យប្រាក់ខ្លួនចំនួន ២០ ដុល្លារ រួចខ្លួនក៏ព្រមលេង ចំណែកឈ្មោះ ភ័ក្រ និងឈ្មោះ ស្រីរ័ត្ន ក៏ឈ្មោះ [redacted] Naswall ឲ្យលេង[redacted]ដែរ ដោយសន្យាឲ្យប្រាក់ ១៥ ដុល្លារ ដែរ ។ ពេលដែលខ្លួ[redacted]គឺនៅខាងក្រៅខោ បន្ទាប់មកគាត់បញ្ចេ[redacted] ។ បន្ទាប់មកឈ្មោះ [redacted] Naswall ក៏បាន[redacted]រួចបានអង្គុយលើម៉ូតូ ហើយគាត់អោនម[redacted] ខ្លួន បានប្រហែល ៣ នាទីក៏ស្រាប់តែសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង ។

ជនរងគ្រោះឈ្មោះ [redacted]ស្រីម៉ៅ បានឆ្លើយថា ខ្លួនស្គាល់ជនបរទេសឈ្មោះ [redacted]Naswall តាំងពីខ្លួនមានអាយុ ១៤ ឆ្នាំ ដោយគាត់ធ្លាប់បានឲ្យប្រាក់មកខ្លួនចាយម្តងៗ ចំនួន ១ដុល្លារ ។ ខ្លួនធ្លាប់បានដើរលេងជាមួយគាត់ បានចំនួន ៣ ទៅ ៤ដង ។ លើកទី១ មិនចាំថ្ងៃខែ ក្នុងឆ្នាំ ២០១១ វេលាម៉ោង ២៤ និង ០០ នាទី ខ្លួនបានទៅជាមួយស្រីណែត ជិះម៉ូតូធំរបស់គាត់ដើរលេង នៅគ្រឹមលេន និងកោះពេជ្រ កន្លែងស្ងាត់គាត់បានឲ្យខ្លួន និងឈ្មោះ ស្រីណែត [redacted]ដោយគាត់សន្យាឲ្យប្រាក់ ៥ដុល្លារ ក្នុងម្នាក់ៗ ប៉ុន្តែពួកខ្លួនមិនព្រម ក៏ដឹកពួកខ្លួនទៅដាក់នៅមាត់ទន្លេវិញ ។ លើកទី២ រូបខ្លួនជាមួយឈ្មោះ ស្រីណែត និងឈ្មោះ ស្រីនាង បានជួបឈ្មោះ [redacted]Naswall នៅសូរិយាម៉ល គាត់បានឲ្យរូបខ្លួន និងឈ្មោះ ស្រីណែត [redacted] រួចគាត់បានឲ្យប្រាក់ខ្លួនម្នាក់ៗ ១០ ដុល្លារ ។ លើកទី៣ នៅថ្ងៃមិនចាំ វេលាម៉ោង ០១យប់ ឈ្មោះ [redacted]Naswall បានយកឡានមកដឹក



Scanned with CamScanner

ខ្លួន ,ឈ្មោះ ស្រីណែត និងស្រីនាង ទៅលេងនៅម្តុំផ្សារកណ្តាល ពេលទៅដល់គាត់បានឈប់ឡានបិទភ្លើង ក៏បានឲ្យពួកខ្លួនទាំងបីនាក់[redacted]រួចគាត់បានឲ្យប្រាក់ពួកខ្លួនក្នុងម្នាក់ៗ ១០ដុល្លារ ។ លើកទី៤ ថ្ងៃខែមិនចាំ វេលាម៉ោង ១យប់ ឈ្មោះ [redacted] Naswall បានយកឡានមកដឹកពួកខ្លួន មានគ្នា ០៤នាក់ ឈ្មោះ ស្រីណែត ,ឈ្មោះ ស្រីនាង ,ឈ្មោះ ស្រីវត្តី ទៅដើរលេង ពេលជិះដល់ផ្លូវលេខ ១៣៦ ឈ្មោះ [redacted] Naswall ក៏បានឈប់ឡាន រួចក៏បានឲ្យពួកខ្លួនទាំងបួននាក់ លេងប្រដាប់ភេទរបស់គាត់ រហូតបានសម្រេចគាត់បានឲ្យប្រាក់ម្នាក់ៗ ១០ដុល្លារ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ[redacted] Naswall គឺខ្លួនមិនបានដឹងទេ ព្រោះខ្លួនមិនបានទៅជាមួយគាត់ ។

ជនរងគ្រោះឈ្មោះ [redacted] មុន្នីរ័ត្ន បានឆ្លើយថា ជនបរទេសជិះម៉ូតូធំ គាត់រស់នៅជិតផ្ទះខ្លួន ហើយគាត់ធ្លាប់ហៅខ្លួនឡើងទៅលេងផ្ទះគាត់ ចំនួន ៨ដង និងធ្លាប់បានឲ្យប្រាក់មកខ្លួន ចំនួន ៨ដង ក្នុងម្តងៗ ចំនួន ២០០០ រៀល ។ ពេលទៅដល់ផ្ទះគាត់ គឺមានរូបខ្លួន និងឈ្មោះ[redacted]មុន្នី ភេទស្រី និងឈ្មោះ គួន ភេទប្រុស ហើយគាត់បានចាប់ដៃខ្លួនឲ្យ[redacted]។

ជនរងគ្រោះឈ្មោះ[redacted]ស្រីឃីម បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted] Naswall ព្រោះគាត់រស់នៅជាន់ទី៦ ជិតផ្ទះខ្លួន ។ នៅថ្ងៃមិនចាំ ឆ្នាំ ២០១៥ តាបារាំងគាត់តែងតែបក់ដៃហៅខ្លួន ឡើងទៅលើផ្ទះរបស់គាត់ នៅជាន់ទី៦ និងធ្លាប់ឲ្យប្រាក់មកខ្លួនជាច្រើនដង ពីចំនួន ៥០០ រៀល ទៅ ១០០០រៀល ។ ពេលខ្លួនឡើងទៅលើផ្ទះគាត់ បានចាប់ដៃខ្លួន [redacted] ពីលើខោលីអូ ។ ចំណែកឈ្មោះ [redacted]មុន្នី ហៅ តី ក៏បាន[redacted] រួចគាត់ឲ្យប្រាក់មកខ្លួន និងឈ្មោះ ស៊ិន [redacted]មុន្នី ម្នាក់ៗចំនួន ១០០០ រៀល ។

ជនរងគ្រោះឈ្មោះ [redacted]មុន្នី បានឆ្លើយថា ខ្លួនបានស្គាល់តាបារាំង ព្រោះគាត់ស្នាក់នៅក្នុងបុរីកីឡាដៃរ គាត់បានឲ្យខ្លួន និងឈ្មោះ [redacted] ស្រីឃីម ហៅ គា ទៅផ្ទះគាត់ ដោយគាត់ឲ្យប្រាក់ម្នាក់ៗ ១០០០រៀល ។ ក្រោយមកតាបារាំងហៅខ្លួន និងឈ្មោះ គា ចូលទៅផ្ទះរបស់គាត់ គាត់ស្លៀកខោលីអូអត់មានពាក់អាវទេ ហើយគាត់បាន[redacted] ពីខាងក្រៅខោ ពេលនោះពួកខ្លួនមានការភិតភ័យ ក៏នាំគ្នារត់ចុះមកក្រោមវិញ ដោយបានប្រាប់រឿងហេតុនេះទៅដល់យាយ ។

ជនរងគ្រោះឈ្មោះ[redacted]ស្រីពៅ បានឆ្លើយថា ខ្លួនធ្លាប់ដើរលេងជាមួយឈ្មោះ [redacted]Naswall បានប្រហែល ៥ ទៅ ៦ដង មកហើយ គឺទៅដើរលេងនៅខ្រឹមលេន និងនៅកោះពេជ្រ នៅក្នុងម៉ោង ២១ និង ០០ នាទី ដោយមានឈ្មោះ ស្រីវត្តី ,ឈ្មោះ ស្រីភ័ក្រ និងឈ្មោះ ក្តាម បានជិះម៉ូតូធំឈ្មោះ [redacted] Naswall ទៅដើរលេងនៅកោះពេជ្រ ពេលទៅដល់កោះពេជ្រ ដល់កន្លែងស្ងាត់ ឈ្មោះ [redacted]Naswall បានឈប់ម៉ូតូ ហើយក៏បានឲ្យពួកខ្លួ[redacted]រហូតបានសម្រេច [redacted] ហើយគាត់ក៏បានឲ្យប្រាក់ក្នុងម្នាក់ៗ ១០ដុល្លារ ។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted]Naswall គឺខ្លួនមិនបានទៅជាមួយគាត់ទេ ហើយអ្នកដែលទៅជាមួយគាត់មានឈ្មោះ ស្រីវត្តី ជាបងស្រីខ្លួន ឈ្មោះ ស្រីភ័ក្រ និងឈ្មោះ ស្រីពេជ្រ ។ ចំណែកខ្លួននៅអង្គុយចាំបងនៅមាត់ទន្លេ រហូតដល់ម៉ោង ២ និង ០០ នាទីយប់ ស្រាប់តែមានមីងរបស់ ស្រីណែត មកប្រាប់ខ្លួនថា បងស្រីខ្លួនឈ្មោះ ស្រីវត្តី ត្រូវសមត្ថកិច្ចឃាត់ខ្លួនជាមួយឈ្មោះ [redacted] Naswall ។

ដើមបណ្តឹងឈ្មោះ[redacted] បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ[redacted]ស្រីពៅ ភេទស្រី អាយុ ១៣ ឆ្នាំ និងឈ្មោះ[redacted]ស្រីវត្តី ភេទស្រី អាយុ ១២ ឆ្នាំ ។ នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥



Scanned with CamScanner

វេលាម៉ោង ២០ និង ០០ នាទី ពេលខ្លួននៅផ្ទះ ស្រាប់តែកូនរបស់ខ្លួនឈ្មោះ ស្រីរ័ត្ន និងស្រីពៅ បានសុំប្រាក់ពីខ្លួន ចំនួន ២០ដុល្លារ ថាទៅទិញស្បែកជើង និងខោអាវនៅផ្សាររាត្រី ។ បន្ទាប់ពីពួកគេចេញពីផ្ទះក៏បាត់រហូត ដល់វេលាម៉ោង ១យប់ ទើបឃើញកូនរបស់ខ្លួន ឈ្មោះ ស្រីពៅ បានមកដល់ហើយប្រាប់ខ្លួនថា ស្រីរ័ត្ន បានទៅជាមួយឈ្មោះ [redacted] Naswall ហើយត្រូវគេចាប់បាត់ហើយ ។ ពេលនោះខ្លួនដើររកកូនរកមិនឃើញ ដល់ស្អែកឡើង ទើបឃើញមានសមត្ថកិច្ចបានទូរស័ព្ទមកប្រាប់ ។ ចំពោះរឿងហេតុដែលជនបរទេស បាននាំកូនខ្លួន [redacted] គឺខ្លួនមិនបានដឹងទេ ខ្លួនសូមប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៦០០០ ដុល្លាអាមេរិក ។

ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ ១៣ឆ្នាំ រឿងហេតុដែលជនបរទេសឈ្មោះ [redacted] Naswall បាននាំកូ[redacted] ភេទរបស់គេនោះ គឺខ្លួនពុំបានដឹងទេ ខ្លួនទើបតែដឹង នៅពេលដែលចាប់ជនបរទេសនោះ ។ កន្លងមកកូនខ្លួនក៏បានប្រាប់ថា វាពិតជាធ្លាប់បានដើរលេងជាមួយជនបរទេសនោះពិតមែន ប៉ុន្តែវាមិនបានប្រាប់ថា វាធ្លាប់ បាន[redacted]ទេ ។ ក្នុងរឿងនេះ ខ្លួនមិនប្តឹងទាមទារសំណងអ្វីទេ ។

ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីល័ក្ខ ហៅស្រីខូច ភេទស្រី អាយុ ១១ ឆ្នាំ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ ពេលខ្លួនមកពីធ្វើការវិញ វេលាម៉ោង ៩ និង ០០ នាទីព្រឹក ស្រាប់តែបាត់កូនស្រីឈ្មោះ [redacted] ស្រីល័ក្ខ ពីផ្ទះដោយមិនដឹងថា វាទៅណានោះទេ រហូតដល់ស្អែកក៏មិនឃើញវា ត្រឡប់មកផ្ទះវិញ រួចខ្លួនក៏បានដើរទៅរកកូន ។ ពេលនោះស្រាប់តែមានអ្នកលក់រថយន្តនៅជិតវត្តភ្នំ ប្រាប់ថា មានជនបរទេសម្នាក់ បានលួងលោមក្មេងស្រី ចំនួន ០៣នាក់ [redacted] ភេទ នៅម្តុំគៀនរបងកោះពេជ្រ ហើយត្រូវប៉ូលីសទន្លេបាសាក់ចាប់ខ្លួន ។ ចំពោះរឿងហេតុដែលជនបរទេសបាននាំកូន[redacted]គឺខ្លួនមិនបានឃើញផ្ទាល់ភ្នែកទេ ។ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៣០០០ដុល្លាអាមេរិក ។

ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ស្រីយឹម ភេទស្រី អាយុ ៧ ឆ្នាំ និងឈ្មោះ [redacted] មុន្នីរ័ត្ន ភេទស្រី អាយុ ៥ ឆ្នាំ ។ នៅក្នុងខែមេសា ឆ្នាំ ២០១៥ កូនស្រីរបស់ខ្លួនឈ្មោ[redacted] ស្រីយឹម បានមកប្រាប់ថា ឈ្មោះ [redacted] Naswall បានហៅវាឲ្យទៅលេងផ្ទះរបស់គាត់ រួចគាត់បាន [redacted] ។ ក្រោយពីប្រាប់ខ្លួនរួច ខ្លួនក៏ប្រាប់កូនថា ថ្ងៃក្រោយឈប់ទៅលេងជាមួយទៀត ។ រំលងបានបីថ្ងៃជនបរទេសនោះ បានមករកកូនខ្លួនដល់ផ្ទះ ប៉ុន្តែខ្លួនមិនបានឲ្យទៅជាមួយនោះទេ ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហេ[redacted] ខ្លួនមិនបានឃើញទេ ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ក្នុងរឿងនេះ ខ្លួនប្តឹងទាម ទារជម្ងឺចិត្តចំនួន ៣០០០ដុល្លាអាមេរិក ។

ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ ១៥ ឆ្នាំ នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ១៩ និង ០០ នាទី ខ្លួនបានបាត់កូនឈ្មោះ [redacted] សុភ័ក្រ ដោយមិនបានដឹងថា ទៅណាទេ ។ រហូតដល់ស្អែក មានអ្នកលក់ឡាននិយាយថា មានជនបរទេសម្នាក់បានលួងលោមក្មេងស្រីចំនួន ៣ នាក់ [redacted] វេលាម៉ោង ២២ និង ០០ នាទី ហើយត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហៅកូន [redacted]ខ្លួនមិនបានឃើញទេ ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៥០០០ដុល្លាអាមេរិក ។



Scanned with CamScanner

ដើមបណ្តឹងឈ្មោះ [redacted]បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ[redacted]ស្រីមៅ ភេទស្រី អាយុ ១៥ ឆ្នាំ នៅថ្ងៃខែមិនចាំ កូនប្រសារខ្លួនឈ្មោះ [redacted]តា បានទូរស័ព្ទប្រាប់ខ្លួនថា កូនរបស់ខ្លួនឈ្មោះ[redacted] ស្រីមៅ ត្រូវខាងសាលាក្រុងចាប់ ។ ចំពោះរឿងហេតុដែលគេចាប់កូនរបស់ខ្លួន យកទៅដាក់នៅកន្លែងអង្គការ ខ្លួនមិនបានដឹងថា មានរឿងហេតុអ្វីទេ ក្រោយមកទើបខ្លួនដឹងថា មានជាប់ពាក់ព័ន្ធ និងជនបរទេសក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៣០០០ដុល្លារអាមេរិក ។

ដើមបណ្តឹងឈ្មោះ [redacted]បានឆ្លើយថា ខ្លួនជាម្តាយបង្កើតរបស់ឈ្មោះ[redacted]អុន្ទី ភេទស្រី អាយុ ៦ ឆ្នាំ នៅក្នុងខែមេសាឆ្នាំ ២០១៥ កូនស្រីរបស់ខ្លួនបានប្រាប់ខ្លួនថា ជនបរទេសម្នាក់ដែលមកជួលផ្ទះ នៅអាគារបេជាន់ទី៦បានហៅវា ឲ្យទៅលើផ្ទះរបស់ជនបរទេសនោះ ។ ដំបូងជនបរទេសនោះបានប្រាប់កូនខ្លួនថា ឲ្យឡើងទៅយកលុយ ស្រាប់តែជនបរទេសនោ[redacted] តែកូនខ្លួនបានចុះមកក្រោមវិញ ។ ចំពោះរឿងហេតុដែលជនបរទេសនោះ ហៅកូនខ្លួនឲ្យ[redacted] ខ្លួនមិនបានឃើញទេ ដឹងតាមកូនប្រាប់តែប៉ុណ្ណោះ ។ ក្នុងរឿងនេះ ខ្លួនប្តឹងទាមទារជម្ងឺចិត្តចំនួន ៥០០០ដុល្លារអាមេរិក ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា៖ ខ្លួនរស់នៅក្នុងសង្កាត់អប៉ុរីកីឡា ហើយធ្លាប់បានឃើញ ឈ្មោះ [redacted]Naswall និយាយលេងជាមួយក្មេងៗ និងទិញនំឲ្យក្មេងៗ ញ៉ាំ និងបានឃើញឈ្មោះ[redacted]Naswall បបួលឈ្មោះ ស្រីទូច ភេទស្រី អាយុ ១២ ឆ្នាំ ទៅដើរលេងនៅមាត់ទន្លេ និងមុខវាំង ហើយខ្លួនបានសួរឈ្មោះ ស្រីទូច ថាតើឈ្មោះ [redacted]Naswall បានប៉ះបាល់រៀងកាយឯងទេ ? ស្រីទូចឆ្លើយថាទេ ឈ្មោះ[redacted]Naswall មិនបានប៉ះពាល់រាងកាយទេ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]ភេទស្រី អាយុ ១៤ ឆ្នាំ បានឆ្លើយថា៖ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៣ វេលាម៉ោង ២១ នង ០០ នាទី ខ្លួនកំពុងសុំលុយភ្ញៀវបរទេសតាមផ្លូវលេខ. ១៣៦ ជិតផ្សារកណ្តាល ក៏បានជួបជនបរទេសឈ្មោះ[redacted]Naswall ហើយបានឲ្យប្រាក់ខ្លួនចំនួន ១ដុល្លារ រួចឈ្មោះ [redacted]Naswall បានបបួលខ្លួនទៅដេកជាមួយគេ ដោយសន្យាឲ្យប្រាក់ ២០ដុល្លារ បន្ថែមទៀត បើខ្លួនព្រមទៅ ។ គាត់និយាយជាភាសាអង់គ្លេស តែខ្លួនចេះស្តាប់បន្តិចបន្តួច ។ នៅថ្ងៃបន្ទាប់មកទៀតខ្លួនព្រមទាំងមិត្តភ័ក្រ ៥ នាក់ទៀត ទៅហូបបាយរួចឈ្មោះ [redacted]Naswall បាននិយាយប្រាប់ខ្លួន និងមិត្តភ័ក្រថា ស្អែករូបគេវិលទៅសហរដ្ឋអាមេរិកវិញ ហើយ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា កាលពីថ្ងៃទីខែមិនចាំ ឆ្នាំ ២០១៣ រូបខ្លួនធ្លាប់បានជួបជនបរទេសឈ្មោះ [redacted] Naswall នៅមុខវាំង បានបបួលខ្លួនឲ្យទៅជាមួយគេ តែខ្លួនប្រកែក ។ ថ្ងៃមួយ [redacted]Naswall បានបបួលប្រពន្ធគេទៅដេកនៅផ្ទះសំណាក់ ប្តីគេដឹងក៏ព្រួតវាយបណ្តាលឲ្យបែកក្បាល នៅជិតផ្សារសូរិយាម៉ល ។ ឈ្មោះ[redacted] Naswall បបួលខ្លួនទៅដេកនៅផ្ទះសំណាក់ គាត់ឲ្យប្រាក់ តែខ្លួនមិនព្រមទៅទេ ។ លុះនៅថ្ងៃបន្ទាប់មកទៀតឈ្មោះ [redacted] Naswall បានបបួលខ្លួនទៅដើរលេងនៅកោះពេជ្រ ពេលនោះមានមិត្តភ័ក្រ ០២ នាក់ទៀតមានឈ្មោះ [redacted] ស្រីណែត និងឈ្មោះ [redacted]រ៉ាន ទៅដល់ជិតស្ពានកោះពេជ្រខាងត្បូង នៅម៉ោង ២៤ និង ០០ នាទី ឈ្មោះ [redacted]Naswall បានឈប់ម៉ូតូ រួចបាន[redacted] ខ្លួនមិនព្រមលេង ខ្លួនក៏ដើរចេញទៅតល់ស្ពាន ។ បន្តិចក្រោយមកខ្លួនបានក្រឡេកឃើញឈ្មោះ [redacted] Naswall [redacted]



Scanned with CamScanner

ឲ្យ ស្រីណែត និងឈ្មោះ [redacted]រ៉ាន [redacted] បានមួយសន្ទុះឃើញឈ្មោះ [redacted] Naswall ឲ្យលុយទៅ ស្រីណែត និងឈ្មោះ ស្រារ៉ាន មិនដឹងថា ប៉ុន្មានទេ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ស្រីធីម បានឆ្លើយថា៖ នៅថ្ងៃមិនចាំខែមិថុនា ឆ្នាំ ២០១៣ ខ្លួនបានជួបឈ្មោះ [redacted] Naswall នៅមុខផ្ទះ គាត់បាននាំពួកខ្លួនដើរលេងផ្សារស៊ីធីម៉ល គាត់ឲ្យលុយខ្លួនចំនួន ៥០០០ រៀល ទិញកាក់លេងហ្គេម និងទិញការ៉េមញ៉ាំ ខ្លួនបានឃើញឈ្មោះ [redacted] Naswall អោបពីក្រោយខ្នងកាទូច ពេលជិះកង់បី ។ នៅក្នុងខែធ្នូ ឆ្នាំ ២០១៣ ខ្លួនបានឃើញឈ្មោះ [redacted] Naswall អោយប្រាក់ ២១ ដុល្លារអាមេរិក ទៅឈ្មោះ ធូ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ទូច បានឆ្លើយថា៖ នៅថ្ងៃខែមិនចាំ ឆ្នាំ ២០១៣ ខ្លួនបានជួបឈ្មោះ [redacted] Naswall ពេលកំពុងឈរចាំមិត្តភ័ក្រ និងបងស្រីទៅដើរលេងឈ្មោះ [redacted] Naswall បាននាំខ្លួនទៅដើរលេងផ្សារស៊ីធីម៉ល គាត់បាអោបចង្កេះខ្លួនពេលកំពុងជិះម៉ូតូកង់បី ។ ក្រោយមកឈ្មោះ [redacted] Naswall បានសន្យាទិញទូរស័ព្ទ អាយហ្វូនឲ្យខ្លួន តែមិនបានឲ្យទេ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនបានស្គាល់ជនបរទេសនោះតែមិនស្គាល់ឈ្មោះទេ ហើយខ្លួនឃើញគាត់ឧស្សាហ៍មកលេងជាមួយក្មេងៗ នៅមុំផ្ទះខ្លួន ហើយក្មេងៗក៏បានសុំប្រាក់ពីគាត់ផងដែរ ។ ឃើញគាត់នៅខាងក្រោយ និយាយលេងជាមួយក្មេងៗ គាត់បានឲ្យប្រាក់ទៅក្មេងៗមាន១ដុល្លារ ២ ដុល្លារ ៥០០រៀល និង ១០០រៀល ។ ខ្លួនធ្លាប់សុំលុយគាត់ចំនួន ៤ដង បានចំនួន ៥០០រៀល ទៅ ១០០០រៀល ១ដុល្លារ និង ២ដុល្លារ ។ ខ្លួនមិនបានទៅដើរលេង រឺឡើងផ្ទះរបស់ឈ្មោះ [redacted] ទេ ។

សាក្សីឈ្មោះ [redacted] កែវ បានឆ្លើយថា៖ នៅយប់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ វេលាម៉ោង ២២ និង ២០ នាទី ខ្លួនបានឃើញជនបរទេសម្នាក់ បានជិះម៉ូតូឌុបក្មេងស្រី ០៣ នាក់ មកឈប់ម៉ូតូនៅខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ រួចជនបរទេសនោះបានឲ្យក្មេងស្រីតូចៗនោះអង្គុយលើម៉ូតូ រួចជនបរទេសនោះ បាន [redacted] ប្រហែល ២នាទី និងរយៈពេល ៥ នាទី ក្រោយមកឃើញជនបរទេសនោះ [redacted] ម្តងទៀត ។ បន្ទាប់ក៏មានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] សុខឡេង បានឆ្លើយនៅសមត្ថកិច្ចថា កាលពីមុនខ្លួននៅអង្គការមិត្តសំលាញ់ រៀនបានប្រហែលមួយឆ្នាំ ក៏បានទៅរៀននៅសាលារដ្ឋ(ហាំងយ៉ោស្រះចក) បានបួនឆ្នាំ ក៏ឈប់រៀន ។ ខ្លួនក៏ដើររើសអេតចាយ និងសុំលុយពីភ្ញៀវ នៅតាមមាត់ទន្លេ ជាមួយមិត្តភ័ក្រមានឈ្មោះ សុភ័ក្រ ,ឈ្មោះ ពេជ្រ ,ឈ្មោះ ក្តាម ,ឈ្មោះ ភី ហៅ រ័ត្ន និងឈ្មោះ ពៅ ដើរពីម៉ោង ៦ ដល់ម៉ោង ៩ យប់ ខ្លួនមកផ្ទះវិញ ។ ខ្លួនធ្លាប់ស្គាល់ជនបរទេស មានឈ្មោះ អាផ្លេ (ប្រាយអ៊ិន) គ្រិះ ស្មៀន ,ឈ្មោះ តូនី ... ខ្លួនមិនបានលុយពីភ្ញៀវទេ ខ្លួនឃើញឈ្មោះ សុភ័ក្រ ,ឈ្មោះ ពេជ្រ និងឈ្មោះ រ័ត្ន ជិះម៉ូតូជាមួយឈ្មោះ អាផ្លេ (ប្រាយអ៊ិន) ៣ ទៅ ៤ដង ។ ពេលពួកគេត្រឡប់មកវិញ ឃើញពួកគេមានលុយ ១០ដុល្លារម្នាក់ៗ ខ្លួនសួរពួកគេដែរតែពួកគេមិនប្រាប់ ។ នៅថ្ងៃខែមិនចាំឆ្នាំ ២០១៤ ខ្លួនធ្លាប់ដើរលេងជាមួយឈ្មោះ គ្រិះ ស្មៀន នៅម៉ាត និងនៅសូ រីយាម៉ល ពេលខ្លះខ្លួនអង្គុយជាមួយឈ្មោះ គ្រិះ ស្មៀន ទល់ភ្លឺ ចាំទិញស្រាឲ្យគាត់ ។ គាត់ឲ្យលុយខ្លួន ៥ដុល្លារ ប្រហែល បួន ទៅប្រាំដង ដែរ ខ្លួនធ្លាប់ឃើញឈ្មោះ ភ័ក្រ និងឈ្មោះ ស្រីរ័ត្ន [redacted] គ្រិះស្មៀន បួន ទៅប្រាំដងដែរ (នៅក្នុងម៉ាត) និងធ្លាប់ឃើញឈ្មោះ ក្តាម



Scanned with CamScanner

,ឈ្មោះ សុភ័ក្រ ,ឈ្មោះ ស្រីរ័ត្ន និងឈ្មោះ ពៅ ទៅជាមួយឈ្មោះ តូនី ពេលពួកគេត្រឡប់មកវិញមានលុយដុល្លា (មិនដឹងចំនួន) ហើយ ពួកក៏មិនប្រាប់ខ្ញុំ ថាធ្វើអ្វីដែរ ។

លោក [redacted] ជានាយការិយាល័យការពារអនីតិជនបានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបានទទួលការរាយការណ៍ពីប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទន្លេបាសាក់ មានករណីរំលោភបំពានផ្លូវភេទលើកុមារ នៅលើកោះពេជ្រ ហើយកំលាំងរបស់លោកក៏បានចុះទៅតាមការរាយការណ៍របស់សន្តិសុខ និងនគរបាលប៉ុស្តិ៍ រហូតឈានដល់ការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក មកសួរនាំនៅកន្លែងសមត្ថកិច្ចរបស់ខ្លួន ។

**មេធាវីការពារឲ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋាន**

នៅក្នុងរឿងនេះ កូនក្តីខ្លួនសុទ្ធតែជាអនីតិជន ការប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់បុរណៈភាពរៀងកាយដល់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ថ្វីត្បិតតែការប្រព្រឹត្តរបស់ជនជាប់ចោទត្រឹម [redacted] និងឲ្យកូនក្តីខ្លួន [redacted] ដោយក៏ទង្វើនេះធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តដល់កុមារីដែលជាជនរងគ្រោះដែរ ។ ហេតុនេះ សុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទរូបនេះទៅតាមផ្លូវច្បាប់ និងសុំឲ្យបណ្តេញជនជាប់ចោទរូបនេះចេញពីប្រទេសកម្ពុជា សុំប្តឹងទាមទារចំណាងដូចការប្តឹងសុំរបស់ដើមបណ្តឹង ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងចម្លើយជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី តំណាងអយ្យការ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក ពិតជាបានប្រព្រឹត្តបទការទិញពេស្យាចារកុមារ កាលពីថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការ សូមតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៣៥៩ អយប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ ទុកដដែល សូមតុលាការពិចារណា និងសម្រេចតាមផ្លូវច្បាប់ ។

**មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន**

ពាក់ព័ន្ធ និងអង្គហេតុនេះ និងចម្លើយរបស់ជនរងគ្រោះ បង្ហាញឲ្យឃើញថា ការដែលកូនក្តីខ្លួននាំជនរងគ្រោះ ទៅដើរលេងពុំមានការបង្ខិតបង្ខំទេ ហើយជនរងគ្រោះសុទ្ធតែម [redacted] ក្នុងគោលបំណងចង់ទទួលប្រាក់កំរៃពីកូនក្តីខ្លួនតែប៉ុណ្ណោះ ហើយជនរងគ្រោះមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ហើយកូនក្តីខ្លួនពុំមានប្រពន្ធ និងពុំមានប្រាក់ទេ ។ ហេតុនេះសុំឲ្យតុលាការប្តូរបទចោទពីបទការទិញពេស្យាចារកុមារ មកបទប្រទូសកេរ្តិ៍ខ្មាសវិញ ដោយសារកូនក្តីខ្លួនជាជនបរទេស ហើយការប្រព្រឹត្តរបស់កូនក្តីខ្លួនពុំមានប៉ះពាល់អ្វីធ្ងន់ធ្ងរដល់ជនរងគ្រោះជាកុមារទេ ។ ហេតុនេះ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

**ជនជាប់ចោទបាននិយាយសំដីចុងក្រោយ**

សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យមកខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយសាក្សី



Scanned with CamScanner

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. តាមរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរនៅក្នុងសំណុំរឿងនេះឃើញថា ពុំមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចឲ្យតុលាការជឿបានថា កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ វេលាប្រហែល ១៩ និង ០០ នាទី នៅចំណុចកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក បានជិះម៉ូតូធំឌុបកុមារីរងគ្រោះចំនួន បីនាក់ មានឈ្មោះ [redacted] ស្រីល័ក្ខ ភេទស្រី អាយុ ១៣ ឆ្នាំ ,ឈ្មោះ [redacted] សុភ័ក្រ ភេទស្រី អាយុ ១៦ ឆ្នាំ និងឈ្មោះ [redacted] ស្រីខ្ញែ ភេទស្រី អាយុ ១៥ ឆ្នាំ ដើរលេង ហូបទំពាំណើ និងទិញសំភារៈផ្សេងៗឲ្យទៅជនរងគ្រោះ ។ ពេលមកដល់កោះពេជ្រ កន្លែងស្ងាត់ ខាងក្រោយឃ្លាំងដាក់ឥវ៉ាន់ ជនសង្ស័យឈ្មោះ [redacted] Naswall ក៏បានឈប់ម៉ូតូ [redacted] របស់គេចេញ ក៏ឲ្យកុមារីរងគ្រោះយក [redacted] រួចគេក៏យក [redacted] រងគ្រោះវិញ ដោយកុមារីរងគ្រោះឈ្មោះ [redacted] ស្រីល័ក្ខ ដាក់អង្គុយលើម៉ូតូ រួចជនជាប់ចោទ បាន [redacted] របស់កុមារីរងគ្រោះវិញ ។ ជនជាប់ចោទបានសន្យាឲ្យប្រាក់ទៅកុមារីរងគ្រោះទាំងអស់នោះ ក្នុងមួយនាក់ៗ ចំនួនពី ១៥ ដុល្លារអាមេរិក ទៅ ២០ដុល្លារអាមេរិក ក្រោយពីជនសង្ស័យឈ្មោះ [redacted] បានធ្វើសកម្មភាពបាន ប្រហែល ០៧ នាទី ក៏ត្រូវសមត្ថកិច្ចចូលទៅធ្វើការឃាត់ខ្លួនជាក់ស្តែងតែម្តងប្រាកដមែន ។ នៅក្នុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ២០១៥ ជនជាប់ចោទឈ្មោះ [redacted] Naswall ក៏បានធ្វើសកម្មភាព ទៅលើកុមាររងគ្រោះជាច្រើននាក់ផ្សេងទៀត ។

២. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] Naswall បានឆ្លើយថា កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ខ្លួនពិតជាបាននាំក្មេងស្រីចំនួន ០៣នាក់ ទៅដើរលេងនៅខ្រឹមលេន និងកោះពេជ្រមែន ដោយជិះម៉ូតូធំរបស់ខ្លួន ។ ខ្លួនពុំបានឲ្យក្មេង [redacted] ះទេ ព្រោះកន្លែងដែលខ្លួនទៅលេងនោះ ជាកន្លែងអូរអរ មានមនុស្សឆ្លងកាត់ច្រើន ខ្លួនពុំហ៊ានធ្វើអ្វីផ្តេសផ្តាសទេ ដែលចម្លើយនេះគ្រាន់តែជាចម្លើយដោះសារប៉ុណ្ណោះ ពុំអាចឲ្យតុលាការជឿបានទេ ។ តាមចម្លើយរបស់កុមារីរងគ្រោះបានឆ្លើយថា កាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ឈ្មោះ [redacted] Naswall នេះពិតជាបាននាំពួកខ្លួនដើរលេងនៅខ្រឹមលេន និងកោះពេជ្រមែន ហើយគាត់បាន [redacted] របស់គាត់ ហើយគាត់បាន [redacted] ហើយគាត់បានសន្យាថានិងឲ្យប្រាក់មកពួកខ្លួន ប្រាក់ដែលគាត់សន្យាឲ្យនោះខ្លួនពុំទាន់បានទទួលទេ ហើយកន្លងមកឈ្មោះ [redacted] Naswall នេះក៏ធ្លាប់បាននាំកុមារីរងគ្រោះទៅ [redacted] ន និង [redacted] រងគ្រោះ ដើម្បីជាថ្នូរនិងប្រាក់ដែលជនជាប់ចោទប្រគល់ឲ្យ ដែលចម្លើយនេះស្រប និងចម្លើយរបស់សាក្សីផងដែរថា ជនជាប់ចោទ



Scanned with CamScanner

ឈ្មោះ [redacted] Naswall ពិតជាបានយកកុមារីរងគ្រោះទៅ [redacted] ខ្លួន និង [redacted] ភេទរបស់កុមារីរងគ្រោះប្រាកដមែន។

ភស្តុតាងទាំងអស់ខាងលើនេះតុលាការអាចលើកយកមកពិចារណាបានតាមមាត្រា ៣២១ នៃក្រម នីតិវិធីព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទឈ្មោះ [redacted] Naswall ជានីតិជនមានស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើសពុំមានជម្ងឺវិបល្លាសស្មារតីទេ ជាសមត្ថជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់។ ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិត ក្នុងការធ្វើឲ្យប៉ះពាល់ដល់បូរណៈភាពរាងកាយរបស់ជនរងគ្រោះជាច្រើននាក់ ដែលផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ដូច្នេះបានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គមដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និងមាត្រា ៣ បានហាមឃាត់ដាច់ខាត និងត្រូវតែផ្តន្ទាទោស ។ម្យ៉ាងទៀតអំពើខាងលើនេះវាមានធាតុផ្សំគ្រប់គ្រាន់ពីបទការទិញសេវាពេស្យាចារកុមារ ។

៥. ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងការខូចខាត និងជម្ងឺចិត្តដូចខាងក្រោម:

ក. ឈ្មោះ [redacted] សុខន ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក

ខ. ឈ្មោះ [redacted] ស្រី ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក

គ. ឈ្មោះ [redacted] សុខា ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក

ឃ. ឈ្មោះ [redacted] ឃាន ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក

ង. ឈ្មោះ [redacted] រៀន ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក

ច. ឈ្មោះ [redacted] រ៉ូហាន់នី ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក

គប្បីតុលាការលើកយកមកពិចារណា តាមព្យសនកម្មរបស់ជនរងគ្រោះ និងលទ្ធភាពរបស់ជនជាប់ចោទ ដើម្បីឲ្យស្របតាមមាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រម នីតិវិធីព្រហ្មទណ្ឌ ។

៦. វត្ថុចាប់យកមាន:

ក. Speaker (ប្រដាប់បំពងសំលេងចំនួន ០២)

ខ. មេម៉ូរីចំនួន ០៤ (ម៉ាក Panasinic 1GB . Wintec 4 GB .Scandisk 4GB . ០១ គ្រឿងទៀតមិនស្គាល់ម៉ាក) ។

គ. CardReader ចំនួន ០២ (ម៉ាកTargus និងម៉ាក Siyoteam) ,ផ្លាសពណ៌ខ្មៅចំនួន ០១ ជើង Memory ចំនួន ០១ និងស៊ីមកាតចំនួន ០៣ ។

ឃ. [redacted] ចំនួន ០២ និងថ្នាំម៉ាក KY ០១ ប្រអប់ ,ស្រោមអនាម័យចំនួន ០៥ ។

ង. ដំបងដែកចំនួន ០១ ,កាំបិតបត់ចំនួន ០៣ ,កាំភ្លើងជ័រចំនួន ០១ និងពិលចំនួន ០១ ។

ច. សៀវភៅកំណត់ហេតុចំនួន ០៥ ក្បាល និងក្រាចំនួន ០១ ។

ឆ. ឯកសារផ្សេងៗមួយចំនួន ,ឌីសមួយចំនួន ,នាមប័ណ្ណមួយចំនួនធំ និងឯកសណ្ឋានអាវប្រយុទ្ធ ០១ ,អាវចាក់ ០២ ។

គប្បីសម្រេចរឹបអូសដើម្បី ស្របតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

ជ. ប៉ាស្ព័រមួយក្បាលលេខ ៥៥៣៦៥១៥៩១ របស់ឈ្មោះ [redacted] DAVID ,ប័ណ្ណបើកបររបស់ឈ្មោះ [redacted] DAVID ចំនួន០១ ,កាត់អេធីអ៊ឹមធនាគារវឌ្ឍនៈរបស់ឈ្មោះ [redacted] DAVID ចំនួន០១ , Passport Card របស់ឈ្មោះ [redacted] DAVID ចំនួន០១ ។

ឈ. ម៉ូតូមួយគ្រឿងម៉ាក Honda XL125 ពណ៌ស្វាទុំ ពាក់ស្លាកលេខ ភព១ ន៦១២៧ ។

ញ. លុយចំនួន ០៣ ដុល្លារអាមេរិក និងលុយខ្មែរចំនួន ១៨.៥០០ រៀល ។

គប្បីតុលាការប្រគល់ឲ្យម្ចាស់ដើមវិញ ។

៦. មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] Naswall ភេទប្រុស អាយុ៥៣ ឆ្នាំ ពីបទការទិញសេវាផ្លូវភេទពីអនីតិជន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ ២០១៥ និងជាក់ស្តែងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

## <u>ហេតុដូច្នេះសម្រេច</u>

១. ផ្តន្ទាទោសឈ្មោះ [redacted] Naswall ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិអាមេរិក ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ ពីបទការទិញសេវាផ្លូវភេទពីអនីតិជន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០១១ ,ឆ្នាំ ២០១៣ ,ឆ្នាំ ២០១៥ និងជាក់ស្តែងនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ អាជីវកម្មផ្លូវភេទ ។

២. បង្គាប់ឲ្យឈ្មោះ [redacted] Naswall សងការខូចខាត និងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម:

ក. ឈ្មោះ [redacted] សុខន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល
ខ. ឈ្មោះ [redacted] ស្រី ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល
គ. ឈ្មោះ [redacted] សុខា ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល
ឃ. ឈ្មោះ [redacted] ឃាន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល
ង. ឈ្មោះ [redacted] រៀន ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល
ច. ឈ្មោះ [redacted] ហាន់នី ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល

ច្រានចោលការទាមទារលើសពីនេះ ។

៣. វត្ថុតាងរួមមាន៖

ក. វត្ថុតាងសម្រេចរឹបអូស មាន:

- Speaker (ប្រដាប់បំពងសំលេងចំនួន ០២)

- មេម៉ូរីចំនួន ០៤ (ម៉ាក Panasinic 1GB . Wintec 4 GB .Scandisk 4GB . ០១ គ្រឿងទៀតមិនស្គាល់ម៉ាក) ។

- CardReader ចំនួន ០២ (ម៉ាកTargus និងម៉ាក Siyoteam) ,ផ្លាសពណ៌ខ្មៅចំនួន ០១ ជើង Memory ចំនួន ០១ និងស៊ីមកាតចំនួន ០៣ ។

- លឹង្គសប្បនិមិត្ត ចំនួន ០២ និងថ្នាំម៉ាក KY ០១ ប្រអប់ ,ស្រោមអនាម័យចំនួន ០៥ ។

- ដំបងដែកចំនួន ០១ ,កាំបិតបត់ចំនួន ០៣ ,កាំភ្លើងជ័រចំនួន ០១ និងពិលចំនួន ០១ ។

- សៀវភៅកំណត់ហេតុចំនួន ០៥ ក្បាល និងក្រាចំនួន ០១ ។



Scanned with CamScanner

- ឯកសារផ្សេងៗមួយចំនួន ,នីសមួយចំនួន ,នាមប័ណ្ណមួយចំនួនធំ និងឯកសណ្ឋានអាវប្រយុទ្ធ ០១ ,អាវប៉ារ៉ា ០២ ។

ខ. វត្ថុតាងដែលត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ មាន:

- ប៉ាស្ព័រមួយក្បាលលេខ ៨៥៣៦៥១៥៩១ របស់ឈ្មោះ [redacted] DAVID ,ប័ណ្ណបើកបររបស់ឈ្មោះ [redacted] DAVID ចំនួន០១ ,កាត់អេធីអឹមធនាគារវឌ្ឍនៈរបស់ឈ្មោះ [redacted] DAVID ចំនួន០១ , Passport Card របស់ឈ្មោះ [redacted] DAVID ចំនួន០១ ។

- ម៉ូតូមួយគ្រឿងម៉ាក Honda XL125 ពណ៌ស្លាទុំ ពាក់ស្លាកលេខ ភព១ ន៦១២៧ ។

- លុយចំនួន ០៣ ដុល្លារអាមេរិក និងលុយខ្មែរចំនួន ១៨.៥០០ រៀល។

៤. សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៦ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner